«ស្អីគេហ្នឹងព្រះ?»

ពីចម្ងាយនៃទិសខាងជើង បានបង្ហើរមកនូវសំឡេងឆ្កែចចកមួយក្បាលផ្សេង ញ៉ាំងឱ្យខ្ញុំត្រូវតែបង្វែរចិត្តបំបែរទៅទីនោះ ប្រមាញ់វាបន្តទៅមុខទៀតដោយព្រងើយកន្តើយនឹងបុរសអាក្រាតមុននេះ។

ជាអារម្មណ៍ព្រងើយកន្តើយមួយ ដែលវាមិនងាយស្រួលនោះទេ ព្រោះគេពិតជាមានរូបរាង «អស្ចារ្យណាស់» ហើយខ្ញុំមិនដែលបានឃើញយូរមកហើយក្រោយពីខានបានមើលរឿង ១៨បូក កាលនៅជំទង់។

ជើងខ្ញុំជាន់ដីសើមនិងដើមឈើងាប់ៗ សម្រាប់ឆ្ពោះទៅរកប្រភពសំឡេងឆ្កែចចកនិងក្លិនឈាម។ ទោះជាយ៉ាងណា មិនបានគយគន់ប្រុសល្អ ក៏ពិតជាបានឡើងសក្តិនឹងគេមិនខានលើកនេះ។

«នៅហ្នឹងមែនទេ?!» ខ្ញុំរអ៊ូពីមុខស្លឹកឈើប្រោកៗនិងបានកាន់ក្តាប់អាវុធមាំមិនលេងធេងឡើយ។

«មានបញ្ហាអីស្រីស្អាត?»

សំឡេងមួយនេះ លាន់មកជ្រាលជ្រៅក្នុងអារម្មណ៍ណាស់ប្រៀន ព្រោះវាស្រទន់ហើយជាសំឡេងបែបប្រុសស្អាតហៅខ្ញុំថា ស្រីស្អាតទៀត? បេះដូងឯកោនេះស្ទើរតែធូរស្រាល ១០០ភាគរយឡើងវិញពីការនឹកដល់រូបរាងសង្ហាមុននេះ។

មនុស្សប្រុសបង្ហាញខ្លួន នៅមុខខ្ញុំដែលភាំងៗ។ គេមានកម្ពស់ខ្ពស់ជាងខ្ញុំ ទៅ៦ចំអាមងណោះពិតមែន!!! នេះបានជាខ្ញុំងើយមើលមុខសង្ហារបស់គេ។ ភ្នែកគេមមីរ មានតណ្ហា មានសញ្ញាស៊ិចនៅបបូរមាត់ ក្រោមស្រមោលព្រះចន្ទដែលពេញពន្លឺពណ៌ប្រាក់ចាំងពាសលើស្បែកមានរោមវែងៗពណ៌មាសរបស់គេ កំពុងបង្កើតចំហេះក្នុងបេះដូងខ្ញុំដោយអនុភាពអាថ៌កំបាំង។

ជាមួយស្នាមញញឹមគ្មានកង្វល់អ្វីទាំងអស់ គេនេះដូចជាកំពុងដើរលេងក្រោមពន្លឺព្រះចន្ទហើយឈប់ដំណើរសម្លឹងមកខ្ញុំដោយស្ងប់ស្ងាត់មិនភ័យ ឬហាក់ដូចជាមិនដឹង មិនខ្វល់ថា ភ្លេចស្លៀកសម្លៀកបំពាក់ហើយខ្លួន!

ខ្ញុំភាំងមិនដឹងត្រូវដោះសារយ៉ាងណាចំពោះអារម្មណ៍ក្រហាមមុខមែនហើយ!

«ឃើញឆ្កែចចកមួយរត់កាត់នេះទេ?»

គេញញឹម ចំកោងសាច់ដុំពោះណែនៗៗៗៗៗ។ ខ្ញុំសម្លឹងតាម ព្រោះមិនអាចជួយខ្លួនឯងឱ្យនឹងនរបានទេ។ រួចភ្នែកខ្ញុំព្រហើនណាស់ វាហ៊ានមើលទៅប្រដាប់របស់គេ ពេញដោយកំពូលភ្នំវែងអន្លាយបះមកលើ អមដោយរុក្ខាតូចៗៗ....

«មើលគ្រប់គ្រាន់ឬនៅ?» គេថាឱ្យខ្ញុំទាំងសំឡេងដូចស្គាល់គ្នា១០០០ឆ្នាំមកហើយ។ ដោយតឹងមុខសែនពិបាកក្នុងការងើបមកមើលមុខគេធ្វើជាមិនអៀន ខ្ញុំបានគ្រវីក្បាលបដិសេធ ដោយខ្មាសអៀនពេញក្នុងក្បាលនេះ។ មនុស្សនេះឈរស្រាតកណ្ដាលយប់ថែមមិនទាញអ្វីគ្របបាំងឡើយពេលឃើញស្រីម្នាក់....

«ហើយ.....»

គេខាំធ្មេញខណៈព្រះចន្ទយាងខ្ពួលយ៉ាងលឿនផ្ដល់ម្លប់ងងឹតមកលើផ្ទៃមុខដោយងើយមុខនិងប្រើគ្រាប់ភ្នែកខ្មៅៗ គ្រហឹមរកព្រះចន្ទ។ «ព្រះចន្ទពេញលេញពីរដង ក្នុងខែតែមួយ កម្រណាស់កូន! វាមានថាមពលខ្លាំង!» ខ្ញុំនឹកភ្លាមដល់ពាក្យមីងហៀងដា។ ជើងខ្ញុំថយក្រោយតិចៗ ព្រោះស្លាបមាសពីរបានត្រដាងចេញមកពីត្រចៀកម្ខាងៗរបស់គេនេះ។ ខ្ញុំថយ គេបោះជំហានមកកៀកខ្ញុំពីខាងក្រោយគុម្ពោតព្រៃ ថ្ពាល់របស់ខ្ញុំឡើងកម្ដៅកណ្ដាលភាពត្រជាក់ស្ទើរកក។

«ពាក់អាវសិនមុននឹងជជែកគ្នាបានទេ?»

ខ្ញុំនិយាយបែបនេះ តែខ្ញុំពិតជាលាក់គោលបំណងសម្ងាត់នៃមនុស្សស្រីម្នាក់ដែលសែនឯកោនិងអផ្សុកយូរណាស់មកហើយ។ ខ្ញុំចង់បានឱកាសជ្រកនៅក្រោមដើមទ្រូងស៊ិចស៊ីប្រភេទរោមល្អិតពេញលេញនេះ។ គ្មានរលូនដង្ហើមបានសោះទោះខំយ៉ាងណាក្ដី។ ដើម្បីបិទបាំងភាពអាម៉ាស់របស់ខ្ញុំ ខ្ញុំបានស្រែកឡើងសួរះ

«មកធ្វើអីនៅហ្នឹង?»

«នេះជាកន្លែងរបស់ខ្ញុំ!»

គេតបត្រជាក់ៗ។

«វាមានគ្រោះថ្នាក់! វាមានចចក! ប៉ូលិស! ខ្ញុំឱ្យលោកចាកចេញ!»

«ដីរបស់ខ្ញុំស្រីស្អាត ហើយខ្ញុំមិនចាំបាច់ពន្យល់អ្វីទៀតទេ! ស្រីស្អាតទេកំពុងរំលោភបំពានលើកន្លែងខ្ញុំ»។

«ហួសហេតុ បន្លាយពេល ខាតពេល» ខ្ញុំនិយាយឡើង។

«ស្អីគេ?» គេសួរស្ទើរខ្សឹប។

«ចម្លែកខ្លួនឯងខ្លះដែរក្នុងការសំងំទីងងឹត ហើយ.....ដើរអាក្រាត.....»

សាជាថ្មីខ្ញុំបានឃើញគេញញឹមសង្ហា រួចបែរចេញទៅវិញ។ ខ្ញុំបានបាត់បង់សតិម្តងទៀតហើយ នៅពេលឃើញខ្នងគេ សាច់ដុំញ័រៗ នៅពេលរាងកាយគេឈានផ្លាស់ទី។

Oh hot boy នៃខ្ញុំ!

«ស្រីស្អាតមកដេញចាប់ឆ្កែចចកតែម្នាក់ឯង កាត់ព្រៃទាំងកណ្តាលយប់...?»

ជាមួយសំណួរគេបែរមកវិញភ្លាមៗ ហើយពេលនេះនៅកៀកពីមុខខ្ញុំតែម្តង។ ខ្ញុំក្រៅពីភាំង ក៏មានអារម្មណ៍ស្រូបទាញចូលចិត្តក្លិនខ្លួនអ័រម៉ូនគេ។ ជាមួយនឹងការស្រមើស្រមៃភ្លាមៗ បើខ្ញុំត្រូវបានគេ...... រអិលចូលមកជិតដល់ទីជម្រៅជាមួយគ្នា នេះជាសុបិនឪប្រេសសិន ឬជាក់ស្តែង?

ម្រាមដៃធំវែងស្តើងនិងងងឹត បានលើកឡើងឈានដល់លាទៅខ្ទប់ពន្លឺព្រះចន្ទពណ៌សស្វាច។ ខ្ញុំមមីរមើលទៅក្រចកដៃគេ ហើយខ្ញុំធ្វើងឹកក្នុងបំពង់កព្រោះវាដូចជាក្រញាំចចក.....

ខ្ញុំឈានថយ តែដៃឆ្វេងគេនៅលើចង្កេះខ្ញុំ ទប់ខ្ញុំយ៉ាងម៉ឺងម៉ាត់ រួចដៃមានក្រញាំមុននេះ ទម្លាក់មកដុសលើផ្លាកសញ្ញាឈ្មោះប៉ូលិសដែលព្យួរនៅលើសុដន់ខាងឆ្វេងរបស់ខ្ញុំ។

«McQuade» គេអាន រួចងើបភ្នែកក្រហមដោយភ្លើងស្នេហ៍ដុតមករកខ្ញុំ។

ខ្ញុំត្រូវងៀងក្បាលទៅក្រោយ គេចកុំឱ្យកៀកនឹងមុខគេពេកព្រោះនេះមិនមែនជារឿងធម្មតាសម្រាប់ខ្ញុំទេ។ ជាធម្មតាខ្ញុំអាចសម្លឹងមើលបុរសស្អាតៗដោយត្រង់ៗមិនគេច ព្រោះថាខ្ញុំកម្របានស្និទ្ធនឹងពួកគេណាស់ បើបានខ្ញុំមិនរំលងឡើយ តែ.....ពួកគេមិនដែលស្រោតបែបនេះទេ។

គេនេះវិញ ធុំក្លិនដូចព្រៃឈើ មានសញ្ញាណស្រស់ស្រាយដូចជាដើមឈើពណ៌បៃតង ភ្នែកមានពណ៌ជាផែនដីពណ៌ត្នោត និង...អ្វីម្យ៉ាង ខ្ញុំមានអារម្មណ៍ថាខ្ញុំធ្លាក់ចូលទៅក្នុងពន្លឺស្រូបទាញនៃភ្នែកគេគ្មានទីបញ្ចប់ទេ។  ថ្ពាល់របស់គេក្រហមព្រោះអាកាសធាតុ បបូរមាត់ក្រាស់មានសាច់ពេញ ម្តងកម្រើក ម្តងរំញ័រ ម្តងសើចរួចរលត់។ ស្បែករបស់គេវិញគឺល្អតតខ្វោះរលោងស្អាតជាងស្បែកខ្ញុំទៅទៀត។

ខ្ញុំបានលូកដៃទាញម្រាមគេចេញពីចង្កេះ ព្រោះវិចារណញ្ញាណជាប៉ូលិសបានវិលមកវិញហើយ។ ដោយសារតែខ្ញុំនៅក្នុងព្រៃស្ងាត់ អាកាសត្រជាក់ ជាមួយបុរសរូបរាងស៊ិចអាក្រាតកាយនិងដ៏ស្រស់សង្ហាម្នាក់ មិនមែនមានន័យថា ខ្ញុំត្រូវទម្លាក់កាំភ្លើង ស្រមៃរកស្នេហ៍ទេ ខានអានខានជក់ជាមួយប្រលោមលោកស្នេហាយូរហើយ ព្រោះខ្ញុំចាស់ជាងតួស្រីក្នុងរឿងអស់នោះឆ្ងាយ។

គេមិនព្រមលែង គេរឹងមាំហើយចចេស។

«ខ្ញុំកំពុងធ្វើការងារ» ខ្ញុំនិយាយរំអុកតែមានលាយអារម្មណ៍ញិកញក់

«ឆ្កែចចកខាំស្ត្រីម្នាក់នៅលើផ្លូវហាយវេ។ ខ្ញុំត្រូវការរករឿងវា»

ភ្នែកគេស្រពោន អ្វីមួយភ្លឺបភ្លែតៗបញ្ចេញមកនៅក្នុងភ្នែករបស់គេហើយបានរលត់ទៅវិញយ៉ាងលឿន មុនខ្ញុំមើលវាយល់។ មិនប្រាកដថា មកពីការផ្លាស់ប្តូរនៃពន្លឺព្រះចន្ទដែលជ្រែកឆ្លងកាត់ស្លឹកនីមួយនៃដើមឈើក្រោមសន្ទឹកខ្យល់បក់នោះទេ។

«ខ្ញុំសង្ស័យថាអូននឹងបានជោគជ័យ Honey» ។ គេថាស្រាលៗដូចសំឡេងប្រេតភីត ហើយបានងាកចេញម្តងទៀតទុកឱ្យខ្ញុំតាមសម្លឹងគល់កសសៃធំៗរបស់គេ ។

«ឌឺខ្ញុំ!!!!» ខ្ញុំថាមួយៗ តែភ្នែកនៅស្រេកឃ្លានដង្ហើមនៃបំពង់ករធំៗរបស់គេ។

«ឌឺអីស្រីស្អាត?»

«ខ្ញុំ....» ខ្ញុំគ្រវីដៃ ដោយមិនមានសម្តីច្បាស់លាស់មកបកស្រាយ។ គេគួរដឹងថា ខ្ញុំមានសម្ពាធព្រោះគេសង្ហាបែបនេះ។ គេព្រមលែងដៃ ហើយដើរបកទៅរកគុម្ពោតវិញ ធ្វើឱ្យខ្ញុំលបគិត«មនុស្សល្ងង់» មិនចេះញ៉ែស្រីទេ។ តែតាមពិតគេមិនបានល្ងង់ទេ ខ្ញុំឃើញគេវិលមកវិញដោយបានដកខោអាវដែលហាលលើមែកឈើសឹង មិនគួរឱ្យជឿតែ....មិនព្រមស្លៀក?

មិនខ្វល់នឹងអ្វីទេ គេក៏ត្រលប់មកវិញហើយមិនយូរសោះ ខ្ញុំបានឃើញខ្លួនខ្ញុំចូលមកផ្អឹបនឹងទ្រូងរបស់គេ។ ដោយវិធីយ៉ាងណាខ្ញុំមិនដឹងទេ គេឱបខ្ញុំលឿនម្ល៉េះ? សាច់គេរលោង ទ្រូងគេរឹងមាំ រោមគេភ្លឺ ធ្វើឱ្យទីនេះល្អឥតខ្ចោះ តើខ្ញុំចោលភារកិច្ចមកភ្លក្សរសជាតិដ៏ឆ្ងាញ់មួយកណ្តាលបេសកកម្មនេះ?

ខ្ញុំញីភ្នែកដើម្បីធ្វើឱ្យរូបភាពដ៏អស្ចារ្យនេះបាំងបាត់ ខ្ញុំត្រូវតែដាស់ភាពជាប៉ូលិស ហើយធ្វើការចាកចេញឱ្យលឿនតាមអាចធ្វើទាំងនៅពេលនេះ ជីពចររបស់ខ្ញុំលោតខ្ពស់ណាស់ ជាការឆ្លើយតបនឹងការគិតប្រឆាំងគ្នា។

ថ្ពាល់របស់ខ្ញុំឡើងកម្តៅខ្លាំង សង្ឃឹមគេមើលមិនឃើញចុះ....

«អ្នកធ្វើឱ្យខ្ញុំ ចង់ហើយស្រីស្អាត!»

គេនិយាយស្រទន់ណាស់ ខ្ញុំកំពុងគិតថាខ្ញុំមិនដែលស្រមៃបានបែបនេះទេ។

«និយាយឡប់?»

ខ្ញុំញញឹមឆ្លើយ ម្រាមខ្ញុំនៅលើចង្កេះដ៏ធំរបស់គេ។

«អូខេ Jessie?»

គេស្គាល់ឈ្មោះខ្ញុំព្រោះបានអានបន្ទះកាតលើអាវ។ អរគុណណាស់ ដែលគេនៅពីលើ ហាក់ដូចជាមិនស្រួលក្នុងការកត់សម្គាល់ឃើញមុខក្រហម និងអណ្តាតស្រក់ទឹកមាត់របស់ខ្ញុំ។

«ខ្ញុំ?»

និយាយបានមួយម៉ាត់ត្រូវផ្អាកព្រោះគេរត់ពេញត្រគាកខ្ញុំ និងជ្រៅជាងនេះស្ទាបរកអ្វីម្យ៉ាង ងក់ក្បាល។ ត្រចៀកគេមានក្រវិល ចាំងពន្លឺផ្លេក។ គេដូចយុវវ័យដែលលេងខ្លួន ឬកូនតណ្ហានៃគ្រួសារចាស់បុរាណអភិជន ដៃគេមានកងដែកពេលប៉ះសាច់ខ្ញុំវាត្រជាក់និងស៊ិចស៊ី។

«ខ្ញុំតាមរកចចក!»

គេបានដកដង្ហើមធំដោយអត់ធ្មត់។

«ខ្ញុំដឹង»

«ខ្ញុំតាមក្លិនឈាមហើយវាបាត់ម្តុំគុម្ពោតដែលលោកចេញមក!» គេងក់ក្បាល។

«លោកប្រាកដទេ ថាមិនបានឃើញស្រមោលចចក?»

គេមិននិយាយតែម្រាមគេឈប់ស្ទាប់លូកខ្ញុំ។

ខ្ញុំនិយាយទៀត៖

«អ៊ីចឹងប្រហែលជាលោកអាចជួយខ្ញុំ ទៅរកគេនៅផ្លូវខាងមុខទៀត?»

គេម្ងូម៉ៅ៖

«ហេតុអ្វីបានជាតាមឆ្កែចចក? ហើយហេតុអីគិតថាខ្ញុំឃើញគេ ដោយសារតែខ្ញុំនៅ Ojibwe?»

«មិនអ៊ីចឹង? មនុស្សស្រុកនេះថ្មីកនឹងរឿងប្រមាញ់មែនអត់?"

គេធ្វើមុខមាំក្រឡេកភ្នែកមើលមកខ្ញុំ។ ខ្ញុំសម្លឹងបបូរមាត់របស់គេ ស្ទើរតែងើយទៅសាកថើបផ្តិត និងហក់ចូលរុករានក្នុងបំពងកគេជាមួយអណ្តាតកំព្រាស្នេហ៍នេះទៅហើយ។ ដូច្នេះគេក៏ស្ទើរតែញញឹមវិញ លែងបង្ហាញអាការៈសៅហ្មងពេលឃើញសេចក្តីទាមទារក្នុងជម្រៅភ្នែកខ្ញុំ។

«ទោះបីជាខ្ញុំដឹង ក៏ខ្ញុំមិនជួយអ្នកណាឱ្យរកឃើញចចកដែរ។ ព្រោះពួកគេនឹងសម្លាប់សត្វ»

ខ្ញុំគ្រវីក្បាលខំពន្យល់គេ

«វាខាំស្ត្រីក្មេងម្នាក់ ខាំខ្លាំង នាងនឹងត្រូវចាក់ថ្នាំបង្ការរោគផ្តេសផ្តាស ប្រសិនបើខ្ញុំរកមិនឃើញ DNA ចចកនោះ»

«អ៊ីចឹងប្រាប់តែម្តង ស្រីស្អាតនឹងរកមិនឃើញចចកនោះទេ» ។

ខ្ញុំធ្វើមុខស្មើព្រោះនឹកឃើញដល់ក្មេងស្រីរបួស។ គេវិញក៏មិនរំខានដោយរឿងនេះ នឹងបានញញឹមស្នេហ៍មកលើខ្ញុំ។

«អ្នកចិត្តវិទ្យាឬគ្រូទាយ?»

«អ្វីមួយក្នុងចំណោមនេះ» គេឆ្លើយហើយញញឹមសង្ហា។

«ខ្ញុំមិនចេញពីព្រៃដៃទទេឡើយ!»

«មិនទទេទេអូន! អូនយកបងនេះផ្ទុកក្នុងបេះដូងទៅជាមួយដែរ!»

ខ្ញុំបានរីករាយចម្លែក ហើយរុញគេចេញទៅវិញតាមរបៀបអៀនអន់និងខ្មាសខ្លួនឯង។ ខ្ញុំច្រានរហូតដល់គេព្រមលែង។ ពន្លឺនៃព្រះចន្ទរសាត់មកវិញ ខ្ញុំឆ្ងល់ថាគេចាប់អារម្មណ៍នឹងមេឃពេកណាស់។

«ក្រចកនេះទុកធ្វើអី? ជាស្ទីលអ្នកប្រមាញ់?»

«ខ្ញុំមិនប្រមាញ់ទេ!» គេឆ្លើយ។

«ចុះ?»

សំឡេងរសឹបនៅពីឆ្ងាយ ខ្ញុំបានឈានជើងចេញពីប្រាណគេហើយបែរក្រោយ។ សម្តាល់បានបន្តិចងាកមកវិញ ប្រុសស្អាតបាត់ខ្លួនភ្លាមៗ ដូចស្រមោលខ្មោច។

អ៊ីចឹងមែន ខ្ញុំបានបន្តដំណើរទៅរកប្រភពសំឡេង តែមាន់ព្រៃរងាវ ឯពេលព្រះអាទិត្យរះឡើង ហើយខ្ញុំនៅតែដៃទទេត្រលប់ទៅកន្លែងកើតហេតុវិញ។

រថយន្តរបស់កញ្ញា Larson ត្រូវអូសទៅឆ្ងាយ ដោយបន្សល់ទុកកម្ទេចកញ្ចក់ ផ្លាស្ទិច និងកំណេកឈាម។

«ហេឡូជេស៊ី»

«ចាស៎!»

ខ្ញុំបានលើកសំឡេងរបស់ហ្សេដាតាមវិទ្យុទាក់ទងហើយឆ្លើយ។

«នាងអើយ! តើកូននៅឯណា? ខ្ញុំភ័យរឿងកូនមានសុវត្ថិភាពដែរអត់?!»

«ខ្ញុំមិនអីទេមីង! ចុះ Brad មិនបានប្រាប់ថាខ្ញុំទៅណាទេ?»

«គេថាឯងចចេសចូលក្នុងព្រៃតែម្នាក់ឯងកណ្តាលយប់!»

«ជាមួយកាំភ្លើងមួយណាមីង" ។

«ហាសហា ថ្ងៃណាមួយ កូននឹងបានជួបមនុស្សឆ្លាតនិងសែនមានន័យម្នាក់ ព្រោះអ្នកគួរឱ្យស្រឡាញ់ណាស់ជេស៊ី»

«ជួបហើយ អូទេ ថ្ងៃណាមួយណ៎ាមីង! យល់ព្រម»

មុខមនុស្សចម្លែក និងអ្វីៗផ្សេងទៀតដ៏រំភើបបានបានភ្លឹបភ្លែតលេចឡើងក្នុងចិត្តខ្ញុំដូចបញ្ចាំងកុន។ ខ្ញុំបានរកឃើញអ្វីប្រសើរដែលមីងហ្សេដាបានប៉ងសម្រាប់ខ្ញុំ គ្រាន់តែខ្ញុំមិនទាន់ចង់ប្រាប់គាត់។

«ចចកបាត់ហើយ» ខ្ញុំនិយាយបន្តទៀត «ហេតុអីបានជាក្រុមយើងមិនឃើញនៅណេះម្នាក់? ឡាននៅហ្នឹង! អូសចេញបន្តិចតែនៅហ្នឹងដដែល?"

«គ្រប់គ្នាមានភាពមមាញឹកបន្តិចនៅក្រោមទីនេះ។ ជម្លោះក្នុងគ្រួសារ ការឈ្លោះប្រកែកគ្នានៅបារ»

«ចុះក្មេងជំទង់ដែលជាជនរងគ្រោះទេ?» ខ្ញុំបានសួរ។

«អីយើងការពារ តែគ្រួសារគេយកចេញបាត់ហើយ!»

«ហះ!» ខ្ញុំតក់ស្លុត។

«កុំស្រែកៗហាននី!»

ពាក្យ Honey ធ្វើខ្ញុំនឹកដល់តាហ្សង់ជាមួយបេះដូងមួយរងាលាយភាពកក់ក្តៅ។ ខ្ញុំរវេវ្នែករំពៃមួយជុំទាំងដឹងហើយថាគេមិននៅទេ។ ប្រហែលជា.....លែងជួបគេហើយដឹង?

ខ្ញុំឮសំឡេងរបស់គេស្រាលស្រទន់ «មិនទទេទេអូន! អូនយកបងនេះផ្ទុកក្នុងបេះដូងទៅជាមួយដែរ!»។ខ្ញុំដកដង្ហើមធំបែរមករកតួនាទីវិញ ខ្ញុំនិយាយបន្ទោសៈ

«ហេតុអ្វីឱ្យនាងចាកចេញ! ទៅបានដោយរបៀបណា? នាងត្រូវបានសត្វព្រៃខាំណ៎ា ត្រូវការបាញ់ថ្នាំផ្អែកតាម DNA»

«ក្រែងរកផ្អែនោះមិនឃើញដដែលទេមែនទេ?!» ហេ្សដាថាមកខ្ញុំក្រៀមក្រំចិត្តណាស់។

«ហេតុអ្វីមិនឃាត់សិន?»

«គ្លីនិកមិនមានសេរ៉ូមគ្រប់ទេ។ ពួកគេអាចទទួលបានពី Clearwater ប៉ុន្តែវានឹងចំណាយពេលជាច្រើនម៉ោងទៀត គ្រួសារគេបានបានបដិសេធក្នុងការប្រថុយរង់ចាំ»

«មានអារម្មណ៍មិនល្អសោះមីងរឿងនេះ!»

«កូនដែលមានអារម្មណ៍ល្អ តាំងពីពេលណាមកម្តង?»

«ហាសហា!» ខ្ញុំសើចរលាក់។

មីងហេ្សដាមានចំណុចល្អមួយដែលកំប្លុកកំប្លែងដាក់អ្នកផង ទាំងជីវិតគាត់ឯកោ។ ខ្ញុំចេញពីការនិយាយជាមួយគាត់ ក៏បានព្យាយាមរក Brad តាមវិទ្យុនៅមិនមានការឆ្លើយតប។

ខ្ញុំចុចទូរសព្ទទៅគាត់ តែគាត់នៅមិនឆ្លើយដដែល។

ព្រះអាទិត្យបានរះឡើងខ្ពស់  ខ្ញុំរឹតអស់កម្លាំង។ ការធ្វើការវេនទីបីនេះ បានធ្វើឱ្យខ្ញុំក្លាយជាបិសាចជញ្ជក់ឈាមដែល មិនគេងលក់នៅពេលយប់ ហើយមិនអាចភ្ញាក់ឡើង នៅពេលពិភពលោករស់រវើក។

«ចចកសម្លាញ់ ខ្ញុំប្តេជ្ញាតាមប្រមាញ់ឯង!»

ខ្ញុំរៀបចំកាំភ្លើងទុក និងចងវិទ្យុហើយបន្ថែមម្នាក់ឯងៈ

«តែនៅពេលក្រោយ ដេកសិនហើយ!»

ប៉ុន្តែជាដំបូង...ខ្ញុំបានក្រឡេកមើលពីក្នុងរថយន្តទៅកាន់កម្ទេចកញ្ចក់ និងផ្លាស្ទិកដែលនៅតែសល់ជ្រងោរនៅលើចិញ្ចើមផ្លូវ ខ្ញុំគិតថាហោចណាស់  ចាប់ចចកមិនបានខ្ញុំត្រូវសម្អាតភាពរញ៉េរញ៉ៃ។

ខ្ញុំបានចុះវិញ ហើយគូសវាសកន្លែងកើតហេតុ វាស់វែងស្លាកស្នាមផ្លូវរអិល រួចយកសំណល់នៃឧបទ្ទវហេតុដាក់ចូលទៅក្នុងថង់ថ្លា។ មានអ្វីមួយផ្សេងចាប់ភ្នែកខ្ញុំជាបន្ទះស្ដើងមួយ ខ្ញុំធ្លាប់ឃើញគេប្រើជាខ្សែក ជាធម្មតាសម្រាប់មនុស្សប្រុស មិនមែនក្មេងស្រីជំទង់ទេ។

អាចទេជាគ្រឿងអលង្ការឬគ្រឿងលម្អ? ខ្ញុំឱនចុះពិនិត្យវាឱ្យកៀកថាក្នុងនោះជាចម្លាក់រូបអ្វី? «សត្វចចក?» ពេលខ្ញុំផ្ដោតសម្លឹងមើលនោះ រូបភាពបានរេររើវាយក្រោមចំហាយខ្យល់ត្រជាក់ ចេញជារូបមនុស្សប្រុស....ខ្នងខ្ញុំបែកញើស ដៃរាងញ័ររប្រើប....ពេលសម្លឹងមុតជាងមុន មុខរបស់មនុស្សចចកបានរលប់វិញ...

«អូខេ! ខ្ញុំស្រវាំងហើយ! ពិតជាត្រូវការគេងខ្លះសិន!»

តើរូបនោះតំណាងជារបស់នរណា? តើវាសំខាន់ទេក្នុងសំណុំរឿងនេះ? សំណួរនេះតាមខ្ញុំដល់ក្នុងឡានប៉ូលិស ខ្ញុំគ្រវីក្បាល ហើយទម្លាក់ភស្តុតាងដាក់ក្នុងកាបូប។ ខ្ញុំមានសំណួរគ្រប់គ្រាន់ដើម្បីឱ្យខ្លួនឯងរវល់ ច្រើននៅពេលព្រឹកព្រហាមអ៊ីចឹង? ចាំយប់នេះចាំរកចម្លើយ។

# រោគឆ្លង

ពេលនេះខ្ញុំគេងបានឆ្អែតជាង៦ម៉ោងហើយ ល្ងាចមកដល់ល្មម។ ខ្ញុំស្រូតរិលមកដល់គ្លីនីកនិងសុំគ្រូពេទ្យថា តើខ្ញុំអាចសួរដំណឹងអំពីជនរងគ្រោះជំទង់នាង Larson ទេ?

«កញ្ញា Larson» ខ្ញុំបានរំឭកគាត់។

«អូ បាទ! ជាជនរងគ្រោះខាំឆ្កែ ដេរប្លួនថ្នេរ ចាក់អង់ទីប៊ីយ៉ូទិកហើយម៉ាដាម!»

«ប៉ុណ្ណឹងទេ?» ខ្ញុំមានអារម្មណ៍មិនល្អឡើយសួរថែម

«ហេតុអ្វីបានជាឱ្យចាកចេញមុនចាក់ថ្នាំឆ្កែ! ចុះបើឆ្កែចចកឆ្កួត?»

«កុំគិតអវិជ្ជមានអីសែហ្វ! ឱកាសអ៊ីចឹងវាតិចតួចណាស់ officer! សត្វឆ្កួតមានទំនោរទៅរកតែប្រចៀវ ឬក្រុមសត្វកកេរ សត្វកណ្តុរ កំប្រុក។» និយាយដល់ណេះពេទ្យផ្អាក គិតមួយភ្លែតទើបបន្ត

«ឬពួកសត្វឆ្មារវង្វេងវង្វាន់យើង ត្រូវការចាក់ថ្នាំឆ្កែឆ្កួត ប្រសិនបើត្រូវសត្វប៉ុន្មាននេះខាំ!» មិនអស់ចិត្តគាត់ប្រាប់ខ្ញុំមកទៀត

«វាមិនទំនងទេដែលចចកកំពុងផ្ទុកជំងឺឆ្កែឆ្កួត! នាងមានសិទ្ធិបដិសេធការចាក់ថ្នាំនោះ»។

ខ្ញុំបន្តដោយត្អូញត្អែរថា៖

«ខ្ញុំចូលចិត្តបញ្ចប់ករណីទាំងអស់ក្នុងដៃរបស់ខ្ញុំឱ្យមានរបៀបរៀបរយ។ ប្រសិនបើមានបញ្ហាដល់អ្នករងគ្រោះខ្ញុំត្រូវរ៉ាប់រង!»

គាត់ដូចខឹងតែប្រឹងសុភាព៖

«ប៉ូលិសអាចតាមដាននាងបាន! នាងដល់វេនហាត់ការ នៅអនុវិទ្យាល័យមួយដែលខានមិនបាន! រកនាងនៅទីនោះចុះម៉ាដាម»

គាត់បានសរសេរអក្សរ complain របស់ខ្ញុំលើក្រដាសរបាយការណ៍។

ខ្ញុំសុំអាសយដ្ឋានរបស់អ្នករងគ្រោះគាត់ក៏ព្រមកត់ឱ្យខ្ញុំ។

«នេះជាអាសយដ្ឋាន របស់ Karen Larson ស្ថិតនៅជិតផ្លូវហាយវេ 199 »

អាសយដ្ឋានរបស់នាងបានពន្យល់អំពីវត្តមានរបស់នាងនៅលើផ្លូវហាយវេ។ យ៉ាងណាក៏ដោយ វាមិនបានពន្យល់ពីមូលហេតុថា ម្តេចបាននាងបើកឡានមកផ្ទះតែម្នាក់ឯងនៅម៉ោង ៣ ទៀបភ្លឺក្នុងមួយយប់ត្រជាក់ខែក្រហមនោះទេ។

អ្នកចំណូលថ្មី?

មនុស្សស្រុកនេះគេជឿលើរឿងព្រេងនិងនិទានព្រះចន្ទក្រហម។

ប្រហែលជាខ្ញុំងឿងឆ្ងល់ លម្អិតពេកហើយ នេះក៏ជារឿងមួយដែលធ្វើឱ្យខ្ញុំវង្វេងនឹងសំណួរខ្លួនឯង តែប្រហែលជានោះដែរ ជាមូលហេតុដែលខ្ញុំក្លាយជាប៉ូលិសម៉ឺងម៉ាត់ម្នាក់។ ងាកមើលព័ត៌មានរបាយការណ៍របស់ពេទ្យម្ដងទៀត កញ្ញា Larson កំពុងហាត់ការជាគ្រូបង្រៀននៅសាលា Treetop Elementary ។

ទោះបីជាសាលារៀនមួយចំនួនត្រូវបានបញ្ចប់នៅមុនថ្ងៃ Memorial Day ចុងសប្ដាហ៍នេះក៏ដោយ ក៏មានសាលាផ្សេងទៀតមមាញឹករហូតដូចជាប៉ូលិសពួកយើងដែរ។

ឡានខ្ញុំឈប់ដល់បរិវេណ Treetop Elementary និងឈានជើងចុះចំពេលមានការស្រែកគំហកយ៉ាងច្រើនទិសច្រលំបល់គ្នា។ អស្ចារ្យហើយ! មានរឿងអី? ហោចណាស់អូខេ ខ្ញុំមានឱកាសជាប៉ូលិសដំបូងនៅកន្លែងកើតហេតុ។

ខ្ញុំក្ដាប់កាំភ្លើងរត់ទៅក្លោងទ្វារធំចំពេលមនុស្សជាច្រើនក្នុងឯកសណ្ឋានសិស្សរត់បញ្ច្រាសមក។

ប្រហែលជាដោយសារតែអ្នកគ្រប់គ្នាចាប់អារម្មណ៍ក្នុងការចេញពីអាគារ ជាងការហៅទៅលេខ 911 បានជាខ្ញុំមិនឃើញអ្នកណាខលទេ។ ម៉េចហ្នឹង? មនុស្សកំពុងរត់តក់ស្លុត ក្មេងៗស្រែកហៅខ្ញុំថា«ឆ្កួតៗ» ។ ខ្ញុំប្រជ្រៀតចូលទៅខាងក្នុងរុញច្រានរលកសិស្សដែលស្លន់ និងដៃរាវរកវិទ្យុមកចុច....

«ហៅកងពិសេស មកTreetop Elementary! មកឱ្យឆាប់! សិស្សបែកខ្ញែកគ្នាច្រើនណាស់! រត់ភ័យស្លន់ ខ្ញុំនៅមិនដឹងរឿងអ្វីច្បាស់ទេ!»

ខ្ញុំបានស្វែងរកសួរព័ត៌មានតែ ដោយសារគ្មានអ្នកណាស្ម័គ្រចិត្តមករវល់នឹងខ្ញុំ ខ្ញុំបានបង្ខំចាប់ដៃមនុស្សពេញវ័យដែលជិតបំផុតម្នាក់។ ពេលប៉ះខ្ញុំ នាងស្រែកយំ ធ្វើឱ្យកុមារជាច្រើននាក់នៅជុំវិញនាងស្រក់ទឹកភ្នែក។ អាកប្បកិរិយារបស់ពួកគេបញ្ឆេះឡើងនូវសុបិនអាក្រក់នៃការបាញ់ប្រហារតាមសាលាដល់ខ្ញុំ។

ទោះបីជាខ្ញុំមិនបានឮសំឡេងកាំភ្លើងក៏ដោយ នោះមិនមានន័យថា មិនមានការបាញ់ផ្ទប់សំឡេងទេ។

«មានរឿងអីនៅក្នុង?» សំឡេងខ្ញុំក៏ញ័រដែរ។

«គ្រូហាត់ការឆ្កួត នាងខាំពួកយើង!»

ខ្ញុំបានរបូតដៃ ដោះលែងនាងដោយឥតព្រាងទុក។